ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកំពត
លេខ: ១១៨/១៦.សសរ

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខ: ៧៥៤១
មកដល់ថ្ងៃទី ០៨.១២.១៦
ម៉ោង ៤:០០

អគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ
ចូល
លេខ: ១១៩
ថ្ងៃទី ០៨,១២,១៦ ម៉ោង ០៩:០០
បញ្ជូន..............

# ដីកា
# ស្តីពី
# ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្តកំពត

## អភិបាល នៃគណៈអភិបាលខេត្តកំពត

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៦/៣១៥ ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ ត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលខេត្តកំពត
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ
- យោងលិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ ស្តីពីសំណើសុំរៀបចំបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ តាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីជំរុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨
- យោងលិខិតលេខ ១៥២០ សជណ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ដើម្បីជំរុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨
- ផ្អែកតាមការងារចាំបាច់របស់រដ្ឋបាលខេត្តកំពត ។

- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពឲ្យបានទៀងទាត់រៀងរាល់ត្រីមាស មកលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ។
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈជូនក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមហាផ្ទៃ ដើម្បីធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជ្រាប និងផ្តល់គោលការណ៍ណែនាំអនុវត្ត ។
- ផ្តល់កិច្ចសហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ តាមរយៈមន្ត្រីបង្គោល ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**ប្រការ៣.-**

ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទក្នុងករណីចាំបាច់សម្រាប់បំពេញតួនាទីភារកិច្ចឲ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរ ។

**ប្រការ៤.-**

បាននិរាករណ៍នូវសេចក្តីសម្រេចលេខ ០៨៥/១៦ ស.ស.រ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ របស់រដ្ឋបាលខេត្តកំពត ស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្តកំពត និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងដីកានេះ ។

**ប្រការ៥.-**

រដ្ឋបាលខេត្តកំពត មន្ទីរ-អង្គភាពជុំវិញខេត្ត សាលាក្រុង ស្រុកគ្រប់ស្រុក និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តដីកានេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កំពត,ថ្ងៃទី ១៣ ខែ ១១ ឆ្នាំ ២០១៦

**អភិបាលខេត្ត**

**ចាន់ ចេស្តា**

***ចម្លងជូន***

- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ